ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
No ១០៤ [illegible]-ឧក

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០០៣

# ប្រកាស

## ស្តីពីការអនុវត្តន៍ប្រព័ន្ធវិសហមជ្ឈការ
## លើការងារគ្រប់គ្រងវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម
## ចំពោះរោងចក្រនៅតាមខេត្ត-ក្រុង ដែលមានទីតាំងនៅឆ្ងាយពីរាជធានីភ្នំពេញ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសឱ្យប្រើច្បាប់បង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥អនក្រ/បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាល កម្ពុជា ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញប្រកាសលេខ ៣៣១ បល/ប្រក ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានបច្ចេកទេសឧស្សាហកម្ម
- បានឃើញប្រកាសលេខ ៤៧៨ លប/ប្រក ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ ១៩៩៩ ស្តីពីដំណើរការប្រព្រឹត្តទៅរបស់មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្ត-ក្រុង

- យោងលិខិតរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាលេខ ៣២៨០ /០៦ កអគ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០២ ស្ដីពីការអនុវត្តនីប្រព័ន្ធវិសហមជ្ឈការ របស់ក្រសួង ស្ថាប័ន ដែលមានសមត្ថកិច្ចពាក់ព័ន្ធ នៅតាមខេត្ត-ក្រុង សំរាប់ការគ្រប់គ្រងរោងចក្រដែលមានទីតាំងនៅឆ្ងាយៗ
- ពិនិត្យសំណូមពរចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ ១ :** ប្រគល់ភារកិច្ចបន្តជូនមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តស្វាយរៀង, កំពង់ចាម, កំពង់ឆ្នាំង, និងក្រុងព្រះសីហនុ ក្នុងការធ្វើអធិការកិច្ច និងធ្វើរបាយការណ៍ បញ្ជាក់ផលិតកម្ម ស្នើសុំវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្មនាំចេញ ដល់រោងចក្រដែលមានទីតាំងផលិតកម្មនៅតាមខេត្ត-ក្រុងរបស់ខ្លួន។

**ប្រការ ២ :** រោងចក្រដែលមានទីតាំងផលិតកម្ម នៅតាមខេត្ត-ក្រុង ដូចមានចែងក្នុងប្រការ ១ អាចសុំវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម នៅតាមមន្ទីរឧស្សាហកម្ម រ៉ែនិងថាមពលខេត្ត-ក្រុងទាំងនោះ ។

**ប្រការ ៣ :** ក្នុងការពិនិត្យសំណើសុំវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្មរបស់រោងចក្រ មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលនីមួយៗត្រូវអនុវត្តដូចតទៅ :

ក/-ចាត់តាំងមន្ត្រីជំនាញចុះធ្វើអធិការកិច្ច តាមខ្សែចង្វាក់ផលិតកម្ម និងធ្វើរបាយការណ៍អធិការកិច្ច ដោយចុះហត្ថលេខាបញ្ជាក់ផលិតកម្ម (តាមគំរូរផ្តល់) រួចប្រគល់ជូនរោងចក្រនៅទីនោះផ្ទាល់ ដើម្បីយកទៅប្រើប្រាស់ជាបណ្តោះអាសន្នជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការសុំនាំចេញផលិតផល ។ ការធ្វើអធិការកិច្ច និងការធ្វើរបាយការណ៍នេះ ត្រូវធ្វើឱ្យបានម៉ត់ចត់ច្បាស់លាស់ ស្របតាមគោលការណ៍សំខាន់ៗនៃសេចក្តីណែនាំរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ចុះថ្ងៃទី ១៦ ខែមិនា ឆ្នាំ ២០០០ ដោយមិនឱ្យលើសរយៈពេលពីរថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យសុំរបស់រោងចក្រ ដែលមានឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវ។

ខ/- បន្ទាប់មកត្រូវរៀបចំឯកសារសុំវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម ផ្ញើមកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល តាមរយៈនាយកដ្ឋានបច្ចេកទេសឧស្សាហកម្ម សុំការសំរេច ដើម្បីយកទៅបំពេញបែបបទជាផ្លូវការនៅក្រសួងពាណិជ្ជកម្មឱ្យបានមុនថ្ងៃសុំនាំចេញទំនិញ។

**ប្រការ ៤** : មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុងនិមួយៗត្រូវធ្វើរបាយការណ៍ ស្តីអំពីសកម្មភាព ស្ថានភាពផលិតកម្ម របស់រោងចក្រផ្ញើមកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល តាមរយៈនាយកដ្ឋានបច្ចេកទេសឧស្សាហកម្ម ឱ្យបានទៀងទាត់រាល់បំណាច់ខែ ។

**ប្រការ ៥** : អគ្គនាយកដ្ឋានឧស្សាហកម្ម នាយកខុទ្ទកាល័យ នាយកដ្ឋានបច្ចេកទេសឧស្សាហកម្ម មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពលខេត្តស្វាយរៀង កំពង់ចាម កំពង់ឆ្នាំង និងក្រុងព្រះសីហនុ ត្រូវអនុវត្តន៍ប្រកាសនេះអោយមានប្រសិទ្ធិភាព ។

រដ្ឋមន្ត្រី

ស៊ុយ សែម

**ចំលងជូន:**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងពាណិជ្ជកម្ម
- មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តស្វាយរៀង
- មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពង់ចាម
- មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពង់ឆ្នាំង
- មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ក្រុងព្រះសីហនុ
- សមាគមកាត់ដេរសំលៀកបំពាក់កម្ពុជា
- សមាគមរោងចក្រស្បែកជើងកម្ពុជា
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ